**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ១៩៩៥៩........អពដ

GENERAL DEPARTMENT OF TAXATION

L20200813002 | TD2432

ថ្ងៃសុក្រ ១០រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង

## ស្តីពី

## ការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែកក្កដា ឆ្នាំ២០២០ និងការស្កេននិងបញ្ជូនលិខិតប្រកាសពន្ធប្រចាំខែតាមសេវាកម្មអនឡាញ

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អ្នកជាប់ពន្ធទាំងអស់ជ្រាបថា យោងតាមការសម្រេចរបស់រាជរដ្ឋាភិបាលដែលបានអនុញ្ញាតឱ្យមន្ត្រីរាជការ និយោជិត កម្មករ ឈប់សម្រាកការងារនៅថ្ងៃទី១៧ ដល់ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០ និងអនុញ្ញាតឱ្យពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែកក្កដា ឆ្នាំ២០២០ ទៅក្រោយថ្ងៃឈប់សម្រាក អគ្គនាយកដ្ឋានពន្ធដារសូមជូនដំណឹងអំពីការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែកក្កដា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ និងពន្យារពេលរហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ សម្រាប់អ្នកជាប់ពន្ធដែលដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (E-Filing)។

ទន្ទឹមនឹងនេះ អ្នកជាប់ពន្ធអាចបន្តអនុវត្តនីតិវិធីស្កេននិងបញ្ជូនលិខិតប្រកាសពន្ធប្រចាំខែតាមសេវាកម្មអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលអ្នកជាប់ពន្ធអាចធ្វើការបញ្ជូនលិខិតប្រកាសពន្ធដោយគ្រាន់តែស្កេនលិខិតប្រកាសពន្ធនិងឯកសារពាក់ព័ន្ធផ្សេងៗហើយបញ្ចូល (Upload) ឯកសារដែលបានស្កេនមកកាន់អគ្គនាយកដ្ឋានពន្ធដារតែម្តងដោយប្រើប្រាស់ប្រព័ន្ធអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service) ដូចមានកំណត់ក្នុងសេចក្តីណែនាំលេខ ៧៧០៥ អពដ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ រហូតដល់មានការជូនដំណឹងជាថ្មី។

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់ថា ការពន្យារកាលបរិច្ឆេទកំណត់ឱ្យដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំខែកក្កដានេះ នឹងជួយសម្រួលនិងផ្តល់លទ្ធភាពគ្រប់គ្រាន់ដល់អ្នកជាប់ពន្ធទាំងអស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh